**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ:១០៣

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥

**សាលដីកា**

លេខ: ៨០

ចុះថ្ងៃទី១១ខែតុលាឆ្នាំ២០០៦

**អាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | វឿល មួន | ចៅក្រម |
| ៤- លោក | ប៉ែន សារឿន | ចៅក្រម |
| ៥- លោក | សោម សិរីវឌ្ឍ | ចៅក្រមរបាយការណ៍ |
| អ្នកស្រី | សុផុន សុមានីកា | ក្រឡាបញ្ជី |

**តំណាងមហាអយ្យការ**

| | | |
|---|---|---|
| លោក | ឈួន ចាន់ថា | ព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០៥"ច" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១០៣ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

**ចំពោះ:** រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៣ តាមមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ត្រឹង អ៊ីម "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៦២ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ២១ E0 ផ្លូវ១២៨ ក្រុមទី២១ សង្កាត់ផ្សារថ្មី II ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ចង់ ហុង (ស) ម្តាយឈ្មោះ ឡៅ ធូ (ស) ប្តីឈ្មោះ លី ប៊ុន (រ) មានកូន០៤នាក់ ។ ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

-មេធាវី : គ្មាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះស៊ុក សារ៉ែន "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីរាជការ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧B ផ្លូវ៦១ សង្កាត់ស្រះចក ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

-មេធាវី : គ្មាន

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះ ស៊ុក សាវ៉ែន បានប្តឹងទាមទារភាគហ៊ុនម្ភៃភាគរយ(២០%) ពីឈ្មោះ ត្រឹង អ៊ីម ដោយហេតុថា កន្លងមកអំឡុងឆ្នាំ១៩៩៣-៩៤ រូបខ្លួន ត្រឹង អ៊ីម និង លី ហ៊ុន បានរួមគ្នាទិញដីទំហំ១១ហ ៧២៧៥ម² + ៥០០០ម² ដែលមានបង្កាន់ដៃទទួលពាក្យ ២៧៣៤០. ២៧៣៤១. ២៧៣៤២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និង ដីច្រើនកន្លែងទៀត នៅភូមិឡូកំបោរ ឃុំស្វាយប៉ាក ស្រុកឫស្សីកែវ ដើម្បីធ្វើអាជីវកម្ម ។ នាង ត្រឹង អ៊ីម បានធ្វើកិច្ចសន្យាថា ចែកភាគហ៊ុនអោយខ្លួនម្ភៃភាគរយ(២០%) នៃហ៊ុនសរុប ហើយភាគហ៊ុននេះ អាចយកលុយនៅពេលលក់ ឬ យកដីទុកនៅពេលណាក៏បានមានសាក្សីជាច្រើនដឹងឮ ។ ដូច្នេះ ខ្លួនក៏សំរេចចិត្តប្រគល់អោយនាង ត្រឹង អ៊ីម ឈរឈ្មោះជាម្ចាស់កម្មសិទ្ធិក្នុងឯកសារផ្សេងៗ និង ទិញដីរៀងរហូតមក ។ ចំណែកខ្លួនមានភារៈកិច្ច ជាអ្នកពិនិត្យលិខិតបទដ្ឋាននានា រៀបចំទុកឯកសារទាំងឡាយដែលពាក់ព័ន្ធក្នុងរឿងដី និង ទទួលបន្ទុកគ្រប់គ្រងថែរក្សា ដោយចេញដើមទុនតាមលទ្ធភាព និង ចេញសោហ៊ុយទិញបង្គោលថ្មី ឬ ឈើដាំព្រំដី និងជួសជុលបង្គោលព្រំជាប្រចាំ ចាប់ពីឆ្នាំ១៩៩៣ រហូតមកពុំដែលមានបញ្ហាអ្វីទេ ទើបតែថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ខ្លួនបានទៅសួរគាត់ ទើបដឹងថា គាត់លបលក់ដី ១២.២២៧នេះ ដោយគ្មានការយល់ព្រមពីខ្លួនដែលមានចំណែក២០%នោះឡើយ ។

-បានឃើញដីកាសំរេចវិធានការបណ្តោះអាសន្នលេខ៤៤៥៣តព្រ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-ហាមឃាត់ឈ្មោះត្រឹង អ៊ីម មិនអោយលក់ដូរ. បញ្ចាំ. ជួល. ផ្ទេរសិទ្ធិ ធ្វើអំណោយទាន ជីកយកដី ចាក់ដី ហ៊ុំព័ទ្ធរបង សាងសង់ផ្ទះ ឬធ្វើប័ណ្ណសំគាល់សិទ្ធិទូវដី ដែលមានបង្កាន់ដៃទទួលពាក្យលេខ២៧៣៤០. ២៧៣៤១. ២៧៣៤២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងបង្កាន់ដៃលេខ ២៧៨១៤. ២៧៨១៥. ២៧៨១៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ និងដីមួយចំនួនទៀត ស្ថិតនៅក្នុងសង្កាត់ស្វាយប៉ាក និង ក្នុងសង្កាត់ឃ្មួញ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាបណ្តោះអាសន្នរង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០០៤ របស់ឈ្មោះត្រឹង អ៊ីម ប្តឹងមិនសុខចិត្តពីដីកាសំរេចវិធានការបណ្តោះអាសន្នលេខ៤៤៥៣តព្រ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើប អង្កេតតុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា:

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះត្រឹង អ៊ីម ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធដីកាសំរេចវិធានការបណ្តោះអាសន្នលេខ ៤៤៥៣ ត.ព្រ ចុះថ្ងៃទី២៣ ខែ

មិថុនា ឆ្នាំ២០០៤ ចោលជាអសារបង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៥ "ច" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះ ត្រឹង អ៊ីម ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធដីកាសំរេចវិធានការបណ្តោះអាសន្នលេខ៤៤៥៣ត.ព្រ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះប៊ិច វិច្ឆិកា ជាមេធាវីតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុក សាវ៉ែន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០៥ "ច" ចុះថ្ងៃទី១១ខែមករាឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា និង សារណាការពារបន្ថែម ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០០៥ របស់ឈ្មោះ ស៊ុក សាវ៉ែន ។

-បានឃើញលិខិតបង្គាប់អោយឈ្មោះ ត្រឹង អ៊ីម ធ្វើសារណាឆ្លើយតប ប៉ុន្តែត្រូវឈ្មោះឈុន ថៃ (ជាកូន) បានទទួលនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ រួចហើយ តែមិនបានដាក់សារណាតប ជូនតុលាការកំពូលវិញទេ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : រឿងនេះ ការហាមឃាត់របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ពុំមែនជាសមត្ថកិច្ច ដែលត្រូវលើកយកមកអនុវត្តទេ ព្រោះភាគីប្តឹងទាមទារក្នុងរឿងកិច្ចសន្យាចែកភាគហ៊ុនតាមភាគរយៈ មិនអាចចាត់ទុកជារឿងព្រហ្មទណ្ឌលើកមកពិចារណាឡើយ ។ ដូចនេះ សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមនីតិវិធីច្បាប់ហើយ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពារចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៥ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស៊ុក សាវ៉ែន ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ ត្រឹង អ៊ីម នាពេលសវនាការថា: នាងខ្ញុំមិនដែលស្គាល់ឈ្មោះ ស៊ុក សាវ៉ែន ទេ ខ្ញុំហ៊ានស្បថ ខ្ញុំឱ្យគេជួយរត់ការឱ្យចេញប្លង់កាន់កាប់ដី អស់ប្រាក់ចំនួន ១០.០០០ដុល្លា ក្រោយមកគេថា មានភាគហ៊ុន ខ្ញុំមិនបានដឹងទេ ។

+ កូន ស៊ុក សាវ៉ែន មិនមានរកស៊ីជាមួយនាងខ្ញុំទេ ហើយថា មានកិច្ចសន្យាបែងចែក

ភាគហ៊ុន ខ្ញុំមិនបានដឹងថា ស្អីផង ព្រោះនាងខ្ញុំមិនចេះអក្សរខ្មែរទេ និងលិខិតកិច្ចសន្យានោះ មិនមានអានឱ្យស្តាប់ទេ ។

សំណូមពរ : សូមតម្កល់តាមសាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : គូភាគីបានប្តឹងផ្តល់គ្នា ទៅតុលាការរដ្ឋប្បវេណី ដែលកំពុងដោះស្រាយនៅឡើយ ។ ចៅក្រមស៊ើបអង្កេតថ្នាក់ក្រោមសំរេចនោះ មិនមែនជាចំណាត់ការក្នុងរឿងព្រហ្មទណ្ឌទេ ព្រោះជាប្រភេទរឿងរដ្ឋប្បវេណីទាំងស្រុង ដូច្នេះសូមតម្កល់សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ និងបញ្ជូនសំណុំរឿងដាក់ចូលតុលាការអង្គសេចក្តី ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី.ចម្លើយរបស់ជនត្រូវចោទឈ្មោះ ត្រឹង អ៊ុម ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ របស់លោកប៊ុច វិច្ឆិកា មេធាវីតំណាងឱ្យលោក ស៊ុក សាវ៉ែន ធ្វើឡើងក្នុងកំនត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំទាន់មានធាតុផ្សំបញ្ជាក់ពីពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ត្រឹង អ៊ុម ពីបទរំលោភលើសេចក្តីទុកចិត្តនៅឡើយ ដូច្នេះការដែលចៅក្រមស៊ើបអង្កេតសំរេចជាវិធានការបណ្តោះអាសន្ន ដែលពុំទាន់មានភស្តុតាងថា មានពាក់ព័ន្ធដល់អំពើល្មើសនោះ ជាការពុំត្រឹមត្រូវទេ ។

-យល់ឃើញថា ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសារណា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៥ គឺជារឿងនៃអង្គសេចក្តី តុលាការកំពូលពុំអាចពិចារណាបានទេ ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី និងជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួន ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះ តុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៥ "ច" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដីចំពោះមុខជនត្រូវចោទ
## កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ១៥ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៥ របស់មេធាវីតំណាងឱ្យលោក ស៊ុក សាវ៉ែន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥"ច" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១០៣ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងនៃអង្គសេចក្ដី ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៦ ។